**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការទំនាក់ទំនងព្រំដែន កម្ពុជា-ថៃ

*********

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការទំនាក់ទំនងព្រំដែន កម្ពុជា-ថៃ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និង ប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
- បានឃើញកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រ

ផ្ទៃឡង់ដី ស្តីពីកិច្ចសហប្រតិបត្តិការព្រំដែន នៅរាជធានីភ្នំពេញ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩៥

- ដើម្បីបង្កើនទំនាក់ទំនងការងារជាមួយកងយោធពលភូមិន្ទថៃ សំដៅការពារសន្តិសុខ ធានាសុវត្ថិភាព តាមបណ្តោយព្រំដែន កម្ពុជា-ថៃ ឱ្យបានល្អប្រសើរ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សំរេច

**មាត្រា ១ :** ត្រូវបានបង្កើតគណៈកម្មាធិការទំនាក់ទំនងព្រំដែនទូទៅ កម្ពុជា-ថៃ ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងការពារជាតិ | ជាប្រធាន |
| ២- អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ | ជាអនុប្រធាន |
| ៣- រដ្ឋលេខាធិការក្រសួងការពារជាតិ | ជាសមាជិក |
| ៤- រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៥- អគ្គស្នងការនគរបាលជាតិ | ជាសមាជិក |
| ៦-អគ្គមេបញ្ជាការរង ឧភម និងជាមេបញ្ជាការកងទ័ពជើងគោក | ជាសមាជិក |
| ៧- រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ជាសមាជិក |
| ៨- រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៩- រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| ១០- រដ្ឋលេខាធិការក្រសួងបរិស្ថាន | ជាសមាជិក |
| ១១- រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ជាសមាជិក |
| ១២-រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | ជាសមាជិក |
| ១៣- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ១៤- តំណាងអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន | ជាសមាជិក |
| ១៥- តំណាងអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការ ដោយសារមីន | ជាសមាជិក |
| ១៦- តំណាងអាជ្ញាធរជាតិប្រេងកាត | ជាសមាជិក |
| ១៧-តំណាងទីចាត់ការគយ និងរដ្ឋាករ | ជាសមាជិក |
| ១៨-តំណាងអាជ្ញាធរជាតិគ្រឿងញៀន | ជាសមាជិក |
| ១៩- ឯកអគ្គរាជទូតកម្ពុជាប្រចាំក្រុងបាងកក . | ជាសមាជិក |
| ២០- អគ្គលេខាធិការ ក្រសួងការពារជាតិ | ជាសមាជិក |
| ២១-អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា | ជាសមាជិក |
| ២២- អគ្គនាយក អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ | ជាសមាជិក |
| ២៣- អគ្គនាយក អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស | ជាសមាជិក |

២៤- នាយរងទី១ សេនាធិការចំរុះ និងជានាយកទីចាត់ការកលយុទ្ធ ជាសមាជិក
២៥- មេបញ្ជាការកងទ័ពជើងទឹក ជាសមាជិក
២៦- មេបញ្ជាការកងទ័ពជើងអាកាស ជាសមាជិក
២៧- នាយក នាយកដ្ឋានស្រាវជ្រាវចារកិច្ចយោធា ជាសមាជិក
២៨- នាយក ទីចាត់ការការងារព្រំដែន ជាសមាជិក
២៩- មេបញ្ជាការកងរាជអាវុធហត្ថ ជាសមាជិក
៣០- នាយក នាយកដ្ឋានទាក់ទងអន្តរជាតិ ក្រសួងការពារជាតិ ជាសមាជិក

**មាត្រា ២ :** បង្កើតគណៈកម្មាធិការថ្នាក់យោធភូមិភាគ សំរាប់ដោះស្រាយការងារតាមមូលដ្ឋានរបស់ខ្លួន ដែលមានសមាសភាពដូចខាងក្រោម :

***យោធភូមិភាគទី ៤ :***

១- មេបញ្ជាការយោធភូមិភាគទី ៤ ជាប្រធាន
២- មេបញ្ជាការរងយោធភូមិភាគទី ៤ ជាអនុប្រធាន
៣- អភិបាលខេត្តព្រះវិហារ ជាអនុប្រធាន
៤- អភិបាលខេត្តឧត្តរមានជ័យ ជាអនុប្រធាន
៥- អភិបាលខេត្តសៀមរាប ជាអនុប្រធាន
៦- បណ្តាមេបញ្ជាការកងទ័ពស្រួច ប្រចាំយោធភូមិភាគទី ៤ ជាសមាជិក
៧- មេបញ្ជាការតំបន់ប្រតិបត្តិសឹករង ព្រះវិហារ សៀមរាប ឧត្តរមានជ័យ ជាសមាជិក
៨- ស្នងការនគរបាលខេត្ត ព្រះវិហារ សៀមរាប ឧត្តរមានជ័យ ជាសមាជិក
៩- ប្រធានមន្ទីរពាណិជ្ជកម្មខេត្តព្រះវិហារ សៀមរាប ឧត្តរមានជ័យ ជាសមាជិក
១០- ប្រធានមន្ទីរសុខាភិបាលខេត្តព្រះវិហារ សៀមរាប ឧត្តរមានជ័យ ជាសមាជិក
១១- ប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រះវិហារ សៀមរាប ឧត្តរមានជ័យ ជាសមាជិក
១២- ប្រធានទីស្នាក់ការគយ និងរដ្ឋាករខេត្តព្រះវិហារ សៀមរាប ឧត្តរមានជ័យ ជាសមាជិក

***យោធភូមិភាគទី ៥***

១- មេបញ្ជាការយោធភូមិភាគទី ៥ ជាប្រធាន
២- មេបញ្ជាការរងយោធភូមិភាគទី ៥ ជាអនុប្រធាន
៣- អភិបាលខេត្តបន្ទាយមានជ័យ ជាអនុប្រធាន
៤- អភិបាលខេត្តបាត់ដំបង ជាអនុប្រធាន
៥- អភិបាលខេត្តពោធិ៍សាត់ ជាអនុប្រធាន
៦- អភិបាលក្រុងប៉ៃលិន ជាអនុប្រធាន
៧- បណ្តាមេបញ្ជាការកងទ័ពស្រួច ប្រចាំយោធភូមិភាគទី ៥ ជាសមាជិក

៨- មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង បន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ ប៉ៃលិន ជាសមាជិក

៩- ស្នងការនគរបាលខេត្ត បន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ ប៉ៃលិន ជាសមាជិក

១០- ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត បន្ទាយមានជ័យ, បាត់ដំបង, ពោធិសាត់, ប៉ៃលិន ជាសមាជិក

១១- ប្រធានមន្ទីរសុខាភិបាលខេត្ត បន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ ប៉ៃលិន ជាសមាជិក

១២- ប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខេត្ត បន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ ប៉ៃលិន ជាសមាជិក

១៣- ប្រធានទីស្នាក់ការគយ និងរដ្ឋាករខេត្ត បន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ ប៉ៃលិន ជាសមាជិក

***យោធភូមិភាគទី ៣ :***

១- មេបញ្ជាការយោធភូមិភាគទី ៣ ជាប្រធាន

២- មេបញ្ជាការរងយោធភូមិភាគទី ៣ ជាអនុប្រធាន

៣- អភិបាលខេត្តកោះកុង ជាអនុប្រធាន

៤- មេបញ្ជាការមូលដ្ឋានសមុទ្រ ( កងទ័ពជើងទឹក) ជាអនុប្រធាន

៥- បណ្តាមេបញ្ជាការកងទ័ពស្រួច ប្រចាំយោធភូមិភាគទី ៣ ជាសមាជិក

៦- មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងកោះកុង ជាសមាជិក

៧- ស្នងការនគរបាលខេត្តកោះកុង ជាសមាជិក

៨- ប្រធានមន្ទីរពាណិជ្ជកម្មខេត្តកោះកុង ជាសមាជិក

៩- ប្រធានមន្ទីរសុខាភិបាលខេត្តកោះកុង ជាសមាជិក

១០- ប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខេត្តកោះកុង ជាសមាជិក

១១- ប្រធានទីស្នាក់ការគយ និងរដ្ឋាករខេត្ត កោះកុង ជាសមាជិក

**មាត្រា ៣ :** គណៈកម្មាធិការទំនាក់ទំនងព្រំដែនទូទៅ កម្ពុជា-ថៃ ត្រូវរៀបចំការិយាល័យទំនាក់ទំនងព្រំដែន កម្ពុជា-ថៃ និងក្រុមការងារតាមច្រកព្រំដែនមួយចំនួន ដែលចាំបាច់ដើម្បីជាជំនួយការដល់គណៈកម្មាធិការនេះ ។ ចំពោះសមាសភាព និងភារកិច្ច អាស្រ័យដោយគណៈកម្មាធិការទំនាក់ទំនងព្រំដែនទូទៅ កម្ពុជា-ថៃ ជាអ្នកកំណត់ ។

**មាត្រា ៤ :** គណៈកម្មាធិការនេះមានភារកិច្ច :

-ដឹកនាំ លើកគោលការណ៍សមស្រប ដើម្បីលើកស្ទួយកិច្ចសហប្រតិបត្តិការ រក្សាសន្តិភាពតាមបណ្តោយព្រំដែន និងទំនាក់ទំនងការងារនៃប្រទេសទាំងពីរ កម្ពុជា-ថៃ ឱ្យបានល្អប្រសើរ ។

-ចេញបទបញ្ជា គោលនយោបាយ និងផែនការឱ្យគណៈកម្មាធិការថ្នាក់យោធភូមិភាគ ការិយាល័យទំនាក់ទំនងព្រំដែន និងក្រុមការងារ ដើម្បីអនុវត្ត ។

-បាត់តាំងគណៈកម្មាធិការឯកទេស ដើម្បីដោះស្រាយរាល់ករណីដែលកើតឡើង ក្នុងក្របខ័ណ្ឌគណៈកម្មាធិការនីមួយៗ ។

**មាត្រា ៥ :** ទីកន្លែងធ្វើការរបស់គណៈកម្មាធិការទំនាក់ទំនងព្រំដែនទូទៅ កម្ពុជា-ថៃ ស្ថិតក្នុងទីស្តីការក្រសួងការពារជាតិ និងចាត់តាំងក្រុមលេខាធិការមួយដើម្បីធ្វើការងារប្រចាំថ្ងៃ ។

**មាត្រា ៦ :** គណៈកម្មាធិការទំនាក់ទំនងព្រំដែនទូទៅ កម្ពុជា-ថៃ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការពារជាតិ ។

**មាត្រា ៧ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៨ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសមាសភាពស្ថិតនៅក្នុងមាត្រា ១ - ២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ